

ចង្កូតនៃរូបកាយ



(4)

នេះគឺជាពាក្យរបស់លោក ដេវេក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> សូមគិតមើលពីសំពៅដែរ វាធំដល់ម្ល៉េះ
> ហើយមានខ្យល់គំហុកបក់ជាត់ទៅផង
> តែនាយកុងបើកទៅមកបានតាមចិត្ត
> ក៏ដោយសារតែចង្កូតយ៉ាងតូចប៉ុណ្ណោះ
> ឯអណ្តាតក៏ជាអវយវៈ១យ៉ាងតូច ដូច្នោះដែរ។ [យ៉ាកុប ៣:៤-៥]

តើអ្នកយល់ពីការប្រៀបធៀបនេះឬទេ? ចង្កូតគឺសម្រាប់ដឹកនាំសំពៅ
អណ្តាតគឺសម្រាប់ដឹកនាំរាងកាយរបស់មនុស្ស និងជីវិតមនុស្ស។
អ្នកមិនចាំបាច់ធ្វើជាអ្នកជំនាញខាងនាវាចរដើម្បីដឹងថា
មនុស្សដែលកាន់ដៃចង្កូតសំពៅជាអ្នកដែលតម្រង់ទិសដៅរបស់សំពៅ
នោះទេ។ ប្រសិនបើដាក់មនុស្សត្រូវដើម្បីកាន់ដៃចង្កូត
សំពៅនោះនឹងធ្វើដំណើរដោយសុវត្ថិភាព
និងមកដល់ទីកំពង់ផែដោយសុវត្ថិភាព។
ប៉ុន្តែប្រសិនបើដាក់មនុស្សខុសដើម្បីកាច់ចង្កូតសំពៅ
ហើយគាត់មិនដឹងថាគាត់កំពុងធ្វើអ្វីនោះទេ
នោះសំពៅទំនងជានឹងត្រូវលិចលង់។
នេះហើយជារបៀបដែលវាស្ថិតនៅក្នុងជីវិតរបស់អ្នក និងនៅក្នុងខ្ញុំ។
ប្រសិនបើមានឥទ្ធិពលត្រូវដែលគ្រប់គ្រងលើអណ្តាតរបស់យើង
យើងនឹងធ្វើដំណើរដោយជោគជ័យឆ្លងកាត់ជីវិត
និងមកដល់គោលដៅរបស់យើងដោយសុវត្ថិភាព។
ប៉ុន្តែប្រសិនបើមានឥទ្ធិពលខុសដែលគ្រប់គ្រងអណ្តាតរបស់យើង
យើងទំនងជានឹងធ្វើឲ្យសំពៅត្រូវលិចលង់មិនខាន។ ដូច្នេះ សូមចាំថា
របៀបដែលអ្នកប្រើអណ្តាតរបស់អ្នកនឹងកំណត់ផ្លូវនៃជីវិតរបស់អ្នកទាំងមូល។
ចូរធ្វើឱ្យវាក្លាយទៅជាគោលការណ៍មួយដែលមានភាពវិជ្ជមាន៖
ដើម្បីបង្ហាញពីជំនឿ និងទំនុកចិត្ត មិនមែនជាការសង្ស័យ
និងការភ័យខ្លាច ត្រូវមានភាពស្មោះត្រង់
និងមិនមែននិយាយបំផ្លើសឡើយ និយាយពីការពិត
និងនិយាយអំពីអ្នកដទៃ
ដូចជាអ្នកចង់ឲ្យមនុស្សផ្សេងទៀតនិយាយអំពីអ្នកដែរ។

ដោយសារតែពាក្យសម្តីក៏គឺជាគ្រាប់ពូជផងដែរ។
ប្រសិនបើអ្នកសាបព្រោះភាពល្ងីងជ្ងរចត់ និងពាក្យប្រមាថ
ពេលមួយអ្នកនឹងទទួលបានផលទ្វេគុណនៅក្នុងជីវិតរបស់អ្នកជាមិនខាន។ ដូច្នេះសូមចាំថា
ត្រូវប្រុងប្រយ័ត្នអំពីរបៀបដែលអ្នកប្រើចង្កូតដែលដឹកនាំសំពៅរបស់អ្នក ចង្កូតនេះគឺជាអណ្តាតរបស់អ្នក។
ចូរទូលសុំព្រះឱ្យជួយប្រើអណ្តាតរបស់អ្នកឱ្យបានត្រឹមត្រូវ។


«យើងមិនគួរអនុ
ញ្ញាតឱ្យអ្វីៗដែលយើងមិនយល់
ធ្វើឱ្យស្មុគស្មាញចំពោះផ្នែកនៃសេចក្តីពិត
ដែលព្រះបានផ្តល់ឱ្យយើងជាមួយនឹង
ការយល់ដឹងច្បាស់លាស់នោះឡើយ
។»
derekprince.com/km/resources
Cut here to use as a bookmark